ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ
លេខ : ០០៦/២១ សណន

# សេចក្តីណែនាំ
## ស្តីពី
## ការអនុវត្តកាតព្វកិច្ចពាក់ម៉ាស និងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាព
## ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ

**រាជធានីភ្នំពេញ** ត្រូវបានក្រសួងសុខាភិបាលចេញសេចក្តីជូនដំណឹងលេខ ០៨៨ **សខល ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១** កំណត់យកថាជាទីតាំងភូមិសាស្ត្រក្នុងចំណោម **៥ រាជធានី-ខេត្ត** មានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុង **"ព្រឹត្តិការណ៍សហគមន៍ ២០-កុម្ភៈ"** ដែលចាំបាច់តម្រូវឱ្យមានការអនុវត្តកាតព្វកិច្ចពាក់ម៉ាស និងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាព ដូចមានចែងនៅក្នុងប្រកាសលេខ **៨១ ស.នក.ប្រក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១** របស់ក្រសួងសុខាភិបាល ស្តីពីកាតព្វកិច្ចពាក់ម៉ាស និងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាព ក្នុងអំឡុងពេលនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ ក្នុងសហគមន៍។

ផ្អែកតាមបទដ្ឋានគតិយុត្តជាធរមាន និងអនុលោមតាមលិខិតលេខ **៨៣៣ សជណ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីភ្នំពេញ** សូមធ្វើការណែនាំដូចខាងក្រោម៖

១. ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ គណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌទាំង១៤ និងមន្ត្រីពាក់ព័ន្ធដែលមាននីតិសម្បទា **ត្រូវផ្តល់ការគាំទ្រ និងចូលរួមសហការឱ្យបានជិតស្និទ្ធជាមួយមន្ត្រីសុខាភិបាលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល** ដើម្បីអនុវត្តការផាកពិន័យអន្តរការណ៍លើបុគ្គល ឬ នីតិបុគ្គល ដែលមិនអនុវត្តនូវកាតព្វកិច្ចពាក់ម៉ាស និងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាព ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ។

២. បុគ្គលទាំងឡាយណាដែលកំពុងស្នាក់នៅ ប្រកបអាជីវកម្ម និងធ្វើដំណើរឆ្លងកាត់ភូមិសាស្ត្ររាជធានីភ្នំពេញ ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវកាតព្វកិច្ចពាក់ម៉ាស និងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាព ដូចមានសេចក្តីសព្វគ្រប់ចែងក្នុង**មាត្រា៣ មាត្រា៤ មាត្រា៥ និងមាត្រា៦ ក្នុងជំពូកទី២** នៃប្រកាសលេខ **៨១ ស.នក.ប្រក** ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ របស់ក្រសួងសុខាភិបាល ស្តីពីកាតព្វកិច្ចពាក់ម៉ាស និងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាព ក្នុងអំឡុងពេលនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ ក្នុងសហគមន៍។

៣. ចំពោះទីកន្លែងដែលតម្រូវឱ្យមានការពាក់ម៉ាស និងទីកន្លែងដែលតម្រូវឱ្យមានការរក្សាគម្លាតសុវត្ថិភាព ត្រូវអនុវត្តឱ្យបានត្រឹមត្រូវ ស្របតាម**ប្រការ៧ ប្រការ៨ និងប្រការ៩ ក្នុងជំពូកទី៣** នៃប្រកាសលេខ **៨១ ស.នក.ប្រក** ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ របស់ក្រសួងសុខាភិបាល ស្តីពីកាតព្វកិច្ចពាក់ម៉ាស និងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាព ក្នុងអំឡុងពេលនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ ក្នុងសហគមន៍ ដែលទីកន្លែងទាំងនោះ មានដូចជា សហគ្រាស គ្រឹះស្ថានឯកជន ភោជនីយដ្ឋាន-អាហារដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ គ្លីនិក មន្ទីរសម្រាកព្យាបាល ឱសថស្ថាន ផ្សារ ហាងលក់ទំនិញ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រោងចក្រ-សិប្បកម្ម ទីកន្លែងធ្វើការ និងទីកន្លែងអាជីវកម្ម ជាដើម។



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

៤. រាល់បុគ្គល ឬ នីតិបុគ្គល ដែលមិនអនុវត្តនូវកាតព្វកិច្ចពាក់ម៉ាស និងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាព ត្រូវផាកពិន័យអន្តរការណ៍ទៅតាមប្រភេទបទល្មើស និងកម្រិតទឹកប្រាក់ពិន័យ ដូចមានចែងនៅក្នុង **ប្រការ២ នៃប្រកាសអន្តរក្រសួងលេខ ១៧៨ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១** របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងសុខាភិបាល ស្តីពីការពិន័យជាប្រាក់ចំពោះបុគ្គល ឬ នីតិបុគ្គល ដែលប្រព្រឹត្តអំពើល្មើសនឹងវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។

៥. ក្នុងពេលចុះសហការបំពេញការងារ មន្ត្រីមានសមត្ថកិច្ច នៃរដ្ឋបាលរាជធានីភ្នំពេញ ត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ និងវិធានការសុខាភិបាលជាប់ជាប្រចាំ ដើម្បីចូលរួមបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍។

ទទួលបានសេចក្តីណែនាំនេះ នាយករដ្ឋបាលសាលារាជធានីភ្នំពេញ ស្នងការនគរបាលរាជធានីភ្នំពេញ មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ អភិបាល នៃគណៈអភិបាលខណ្ឌទាំង១៤ ប្រធានមន្ទីរសុខាភិបាលរាជធានីភ្នំពេញ ប្រធានមន្ទីរ-អង្គភាពជំនាញពាក់ព័ន្ធ ក្រុមការងារគ្រប់គ្រងទីតាំងចត្តាឡីស័ក និងម្ចាស់ទីតាំងចត្តាឡីស័កឯកជន ព្រមទាំងក្រុមបុគ្គលដែលកំពុងធ្វើចត្តាឡីស័កទាំងអស់ ត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ឱ្យទទួលបានលទ្ធផលល្អ និងការទទួលខុសត្រូវខ្ពស់៕

ថ្ងៃសៅរ៍ ១៤ កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០២១

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល

*"ដើម្បីជូនជ្រាបជាព័ត៌មាន"*

- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
- រដ្ឋបាលខណ្ឌទាំង១៤
- មន្ទីរ-អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានីភ្នំពេញ

"ដើម្បីមុខការ"

- **ឯកសារ-កាលប្បវត្តិ**



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh